

កម្រងសិក្សាកថាខ្មែរ
ឧទ្ទិសប្រគេន ព្រះធម្មរាមោ ប៉ុណ្ណ-សុម្ភាជ
ប្រមូលចងក្រង និងរៀបចំបោះពុម្ពដោយ បណ្ឌិត ឃីង ហុកឌី
Khmer Studies in Honour of Venerable PONN Sompheach
Etudes khmères en hommage au Vénérable PONN Sompheach
Dr. KHING Hoc Dy (Ed.)
Editions Angkor
2011

# លំនាំដើម

កម្រងសិក្សាកថាខ្មែរនេះបដិសន្ធិឡើងចេញពីចិត្តសទ្ធាជ្រះថ្លា នៃសិស្សគណចាស់ព្រះធម្មាភាមោប៉ុណ្ណសុម្គាជ នៅមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រក្រុងភ្នំពេញនិងអ្នកធ្លាប់រាប់អានព្រះគ្រូ។ សមូហកម្មនេះជាវិភាគទានរួមនៃសិក្សាកថាខ្មែរដែលអ្នកស្រាវជ្រាវជាតិយើងមានចេតនាចង់ឧទ្ទិសប្រគេនព្រះគ្រូដែលជាអ្នកប្រាជ្ញជាតិបានបូជាព្រះជន្មបម្រើព្រះពុទ្ធសាសនានិងវប្បធម៌អរិយធម៌ខ្មែរហើយ ព្រះអង្គទៀតសោតបានផ្ទេរចំណេះដឹងមកសិស្សគណនិងពុទ្ធបរិស័ទខ្មែរជាទូទៅដោយយក ព្រះទ័យទុកដាក់បំផុត។សៀវភៅស្នាដៃរួមនេះជាសក្ខីភាពនៃការរំឭកឧបការគុណព្រះគ្រូនិងជាគារវភក្តីនៃយើងខ្ញុំទាំងអស់គ្នាចំពោះព្រះគ្រូ។

កម្រងសិក្សាកថានេះមានទាំងអស់ ១៦អត្ថបទសិក្សាស្រាវជ្រាវជាភាសាខ្មែរ,ភាសាបារាំងនិងភាសាអង់គ្លេសដោយចែកចេញជាប្រាំបង្គោមធំៗ៖

១)ជីវប្រវត្តិព្រះធម្មាភាមោប៉ុណ្ណសុម្គាជនិងបរិបទជុំវិញព្រះអង្គ

២)ព្រះពុទ្ធសាសនានិងទ្រឹស្តី

៣) ព្រះពុទ្ធសាសនានិងសង្គម

៦) ព្រះពុទ្ធសាសនានិងអក្សរសិល្ប៍

៧)ប្រវត្តិសាស្ត្រ។

ក្នុងចង្កោមទី១ស្តីពីព្រះធម្មាភាមោប៉ុណ្ណសុម្ភាជនិងបរិបទជុំវិញព្រះអង្គមានអត្ថបទបណ្ឌិតឃីងហុកឌីបង្ហាញពីជីវប្រវត្តិជាសារុបលើព្រះធម្មាភាមោ, បន្ទាប់មកមានសេចក្តីសម្ភាសន៍របស់អ្នកស្រីអ៊ីងជាភាវិចិត្រ-ចាយជាមួយអ្នកស្រីហាត់ព្រៃជាប្អូនស្រីបង្កើតរបស់ព្រះអង្គហើយបន្តដោយអត្ថបទជាភាសាបារាំងនិពន្ធឡើងដោយលោកចាន់លេខាបច្ចុប្បន្ននាយក«គេហស្ថានខ្មែរ»ក្នុងបុរីសាកលវិទ្យាល័យក្រុងប៉ារីសស្តីពី«ជីវិតលោកគ្រូប៉ុណ្ណសុម្ភាជនៅក្រុងប៉ារីស»ហើយបញ្ចប់ចង្កោមនេះដោយអត្ថបទលោកធួចគីមស្នូកំជាសេចក្តី«ឧទ្ទិសកុសលប្រគេនព្រះវិនវ័តប៉ុណ្ណសំភាជ»[1]។

ចង្កោមអត្ថបទទី២គឺនិយាយពីទំនាក់ទំនង ទ្រឹស្តីក្នុង ព្រះពុទ្ធសាសនាមានអត្ថបទសិក្សាបណ្ឌិតចោងដែលស្តីពី«បដិសន្ធិ ឬ តំណកពកំណើតព្រះពុទ្ធសាសនា»,បន្ទាប់មកមានអត្ថបទលោកឃីងដំស្តីពី«កល្យាណធម៌»គឺជា ផ្លូវនាំទៅរកសេចក្តីសុខស្ងប់នៅក្នុងជីវិតប្រចាំថ្ងៃរបស់បុគ្គលម្នាក់ៗ និងជាធម៌ទ្រទ្រង់លោកឲ្យគង់វង្សឋិតថេរៗសេចក្តី

[1] អក្ខរាវិរុទ្ធព្រះនាមលោកមានដូចតទៅះប៉ុណ្ណសំភាជ,ប៉ុនសំភាជ, ប៉ុណ្ណសុម្ភាជ,ប៉ុណ្យសុម្ភាជ,ប៉ុណ្ណសម្ភាជន៍។តែអក្ខរាវិរុទ្ធព្រះនាមលោកច្រើនជាងគឺប៉ុណ្ណសុម្ភាជ។

សុខ សុភមង្គលក្នុងគ្រួសារនឹងកើតឡើងបានអាស្រ័យមានមេត្តាធម៌ អព្យាស្រ័យ អនុគ្រោះសន្តោសប្រណីគ្នា ជាមូលដ្ឋាន។សមាជិកម្នាក់ៗ ក្នុងគ្រួសារក្តី ក្នុងសង្គមក្តី គប្បីប្រកាន់យកនូវគោលធម៌សន្តិភាព ទុកជាមាគ៌ាក្នុងទំនាក់ទំនង រវាងគ្នានឹងគ្នា ដោយគោរពគ្នាទៅវិញមក ដោយផ្អែកលើច្បាប់សីលធម៌ ឬច្បាប់សង្គម ទើបអាចរួមរស់ នៅជាមួយគ្នាបានដោយសុខដុមរមនា។ការអប់រំសន្តិភាពតាមបែបព្រះពុទ្ធសាសនាបានបង្ហាញមាគ៌ាមួយ មានឈ្មោះថា«កល្យាណធម៌» សម្រាប់អ្នកស្រឡាញ់ជីវិតរបស់ខ្លួននិងជីវិតមនុស្សសត្វដទៃ អ្នកចង់រស់នៅដោយសេចក្តីសុខស្ងប់ក្នុងសង្គម និងសុភមង្គលក្នុងគ្រួសារ បដិបត្តតាម។ កល្យាណធម៌នេះ គឺជាធម៌គូគ្នានឹងសីលប្រាំដែលពុទ្ធបរិស័ទជាគ្រហស្ថទាំងឡាយត្រូវបតិបត្តជានិច្ចសីលប្រចាំថ្ងៃ។ចង្អុលម៉ាមទី២នេះ បញ្ចប់ដោយអត្ថបទសិក្សាបណ្ឌិតថោដដែលជាភាសាអង់គ្លេសស្តីពី «ទំនាស់ទំនុយ និងដំណោះស្រាយជម្លោះ តាមបែប ក្នុងព្រះវិន័យបិដក»គឺជាការសាកល្បងអធិប្បាយអំពីដំណោះស្រាយជម្លោះ តាមបែបព្រះពុទ្ធសាសនា ដោយពឹងផ្អែកទៅលើព្រះវិន័យបិដក ក្នុងវិស័យអធិករណ៍ផ្នែកព្រះសិក្ខាបទ។ អ្នកនិពន្ធមានបំណងពីរគឺ ទី១ធ្វើឲ្យងាយស្រួល ល្មមដល់ការយល់បានដល់ពុទ្ធបរិស័ទជាទូទៅ។ ទី២ ស្នើយោបល់ក្នុងកិច្ចអនុវត្តន៍ ដោះស្រាយវិវាទផ្សេងៗ ក្នុងសង្គមពុទ្ធបរិស័ទដោយពឹងផ្អែកទៅលើដំណោះស្រាយ ដែលមានចែង ក្នុងគម្ពីរព្រះវិន័យបិដក។ កិច្ចការនេះត្រូវធ្វើទៅជាសហប្រតិបត្តិការ ឲ្យស្របគ្នានឹងច្បាប់រដ្ឋ ដែលមាននៅជាធរមាន។អត្ថបទជាភាសាអង់គ្លេសនេះ ចែកចេញជាប្រាំពីរចំណែក។ផ្នែកទី១ ស្តីពីទ្រឹស្តីជាមូលដ្ឋានរបស់អធិករណ៍ ផ្នែកទី២ប្រភេទអធិករណ៍ ផ្នែកទី៣ដំណោះស្រាយ

អធិករណ៍ ផ្នែកទី៤ដំណាក់ការស៊ើបអង្កេត ក៏ដូចជាការធ្វើការសម្រេចពីពេលមុន ផ្នែកទី៥អធិករណ៍នៅកោសម្ពី ផ្នែកទី៦ដំណោះស្រាយអធិករណ៍នៅកោសម្ពី ផ្នែកទី៧សំនើបែបបទអនុវត្តក្នុងសង្គមព្រះពុទ្ធសាសនា។ ដំណោះស្រាយអធិករណ៍តាមបែបព្រះពុទ្ធសាសនា គឺមិនមានការចំណាយប្រាក់កាសពីគូវិវាទទេ មិនមានការផាកពិន័យតម្រូវឲ្យបង់ប្រាក់កាសទេព្រមទាំងមិនមានការដាក់គុកច្រវាក់ទេ។

ចង្កោមអត្ថបទទី៣ស្តីពី«ព្រះពុទ្ធសាសនានិងសង្គម»គឺមានអត្ថបទលោកឡៅ សារុជ ពិពណ៌នាពី«តួនាទីវត្តអារាមក្នុងសង្គមខ្មែរ», អត្ថបទសាស្ត្រាចារ្យវ៉េសុជារ៉ា បង្ហាញពី«តួនាទីព្រះសង្ឃខ្មែរនៅសតវត្សទី១៦-១៩»ដោយផ្អែកលើឯកសារសិលាចារឹកជាគោល។ក្នុងចង្កោមនេះលោកឌីកាបេត បានពិពណ៌នាជាភាសាបារាំងពី«តួនាទីសាសនាក្នុងនយោបាយខ្មែរ»ជាពិសេសគឺព្រាហ្មណ៍សាសនា និងពុទ្ធសាសនាតាំងតែពីបុរាណកាលមក។លោកជុត ខៃ បានបង្ហាញពី«មាតុភូមិនិងវីរបុរសខ្មែរ»គឺមានការពាក់ព័ន្ធនិងពុទ្ធសាសនាជាចាំបាច់ហើយបាននិយមន័យពាក្យមាតុភូមិដោយផ្អែកទៅលើទ្រឹស្តីទស្សនវិទូធំៗនិងរំលឹកពីកិត្តិនាមវីរជនខ្មែរយើងមួយចំនួន។

ចង្កោមទី៤គឺស្តីពីអក្សរសិល្ប៍ទំនៀមខ្មែរពាក់ព័ន្ធនិងព្រះពុទ្ធសាសនាយ៉ាងស្អិតរមួតដោយបង្ហាញដោយបណ្ឌិតឃីង ហុកឌី លើអត្ថបទសិក្សាពីរគឺ«កំណាត់គតិលោកស្នាដៃសុត្តន្តប្រីជាឥន្ទ»និង«សិក្សាកថាមហាវេស្សន្តរជាតក»។

ចង្កោមទី៥គឺកម្រងអត្ថបទសិក្សាបែបប្រវត្តិសាស្ត្រមាន អត្ថបទសាស្ត្រាចារ្យបណ្ឌិតមីកាអ៊ីកឺជាភាសាបារាំងបង្ហាញពី«តារាងព្រះមហាក្សត្រខ្មែរតាមលំដាប់លំដោយតាំងតែក្រោយសម័យអង្គររហូតមកដល់

បច្ចុប្បន្នកាល-ពោលគឺចាប់តាំងពីពាក់កណ្ដាលសតវត្សទី១៤មករហូតមកដល់សព្វថ្ងៃនេះដោយផ្អែកជាពិសេសលើឯកសារព្រះរាជពង្សាវតារក្រុងកម្ពុជា។ក្នុងចង្កោមចុងក្រោយនេះមានអត្ថបទសិក្សាជាភាសាបារាំងមួយធំទៀតដោយបណ្ឌិតឃីផាន់រ៉ា ស្ដីពី-អង្គរ. សាកល្បងអានអរិយធម៌និងប្រវត្តិសាស្ត្រ-នេះជាការសិក្សាបែបសំយោគដោយល្បងមើលឡើងវិញនូវអរិយធម៌និងប្រវត្តិសាស្ត្រខ្មែរនៅសម័យអង្គរបន្ទាប់ពីបានឃើញ-អត្ថបទចំនួនដ៏ច្រើនហួសការគណនា បាននាំឱ្យយើងស្គាល់ជ្រួតជ្រាបពី អរិយធម៌ និងប្រវត្តិសាស្ត្រអង្គរ ។ ឥឡូវនេះតើយើងអាចផ្ដោតចក្ខុឱ្យបានឆ្ងាយ ផុតពីហេតុការណ៍នយោបាយ ពីព្រឹត្តិការណ៍ចម្បាំងពង្រីកទឹកដី ពីការស្ថាបនា ប្រាង្គប្រាសាទ ពីសំណង់ប្រព័ន្ធធារាសាស្ត្រ ។ល។ បានដែរឬទេ?។ បញ្ញត្តិ (concept)ខ្លះនៃវិទ្យាសាស្ត្រសង្គម បានផ្ដល់បទបង្ហាញក្នុងការសិក្សាស្រាវជ្រាវពីអរិយធម៌និងប្រវត្តិសាស្ត្រ និងក្នុងការលើកជាសំនួរនូវបញ្ហាមួយចំនួន ។ ទ្រឹស្ដី ទាក់ទងពី « ជីវិតនៃអរិយធម៌ cycle de vie des civilisations » នឹងជួយបញ្ជាក់ លក្ខណវិនិច្ឆ័យសម្រាប់វិភាគលើការកកើត ការរីកចម្រើន និងការឱនថយ នៃអរិយធម៌អង្គរ ។ បញ្ញត្តិស្ដីពី « ប្រវត្តិសាស្ត្របែបមនោគមវិជ្ជា histoire idéologique » នឹងជំរុញឱ្យយើងយកចិត្តទុកដាក់លើ « រឿងព្រេង » ដែលទាក់ទងនឹងប្រវត្តិសាស្ត្រ និងលើ « ចិត្តគំនិតនៃប្រជាជាតិ mentalité collective »។ ការបកស្រាយពីសង្គម និងពីសេដ្ឋកិច្ចនឹងនាំយើងទៅសិក្សា « រដ្ឋធារាសាស្ត្រ État hydraulique » ដោយផ្អែកលើបញ្ញត្តិ « ទីក្រុងធារាសាស្ត្រ cité hydraulique», លើបញ្ញត្តិ « ការបង្កើតផលបែបទម្រង់អាស៊ី mode production asiatique » និង

លើបញ្ញត្តិ « អត្តាសាធិបតេយ្យបែបបូព៌ាdespotisme oriental» ។" បញ្ហាចោទនិងដោះស្រាយ,បណ្ឌិតឃីផាន់ក៏បានវិភាគក្នុងសំយោគកថា លោកដូចមានសេចក្តីសង្ខេបខាងលើនេះស្រាប់។

អត្ថបទចុងក្រោយក្នុងចង្កោមនេះគឺជារបាយការណ៍របស់សមាគមពុទ្ធសាសនាខ្មែរនៅប្រទេសបារាំងនាពេលជំនុំនៅវត្តវាំងសែនក្រុងប៉ារីសនិពន្ធឡើងដោយបណ្ឌិតចាយមីស្ទែលជាភាសាបារាំងហើយលោកបានបង្ហាញផងដែរនូវប្រវត្តិពុទ្ធសាសនាដែលបានហូរ ចូលមកក្នុងប្រទេសបារាំង។លោកបានបញ្ជាក់ទៀតថាព្រះពុទ្ធសាសនានៅកម្ពុជារីក ដុះដាល ដោយបានទទួលការជួយគាំទ្រពី "សមាជិកអង្គការ ហ្វ្រង់ម៉ាសុង គ្រង់អូរីយ៉ង់ដឺហ្វ្រង់ " (Franc-maçonnerie du Grand Orient de France) ដែលបដិសន្ធិឡើង នៅភ្នំពេញ នាថ្ងៃ១០មិថុនា១៩០៧។

បណ្ឌិតឃីងហុកឌី